## ការសិក្សាលើមាត្រានីមួយៗ

### ប្រធានបទ

### ស្តីពី

# ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ

(គន្ថីទី១ មាតិកាទី១ ជំពូកទី២ និងទី៣ នៃក្រមព្រហ្មទណ្ឌ)

រៀបរៀងដោយ៖ ន.ស.រ

ខែមករា ឆ្នាំ២០១៧

# មាតិកា

## ផ្នែកទី១

### ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

## ផ្នែកទី២

### ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ

ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ សំដៅដល់ការកំណត់ទុកជាមុននូវដែនកំណត់ច្បាស់លាស់មួយ ដើម្បីឲ្យដឹងថា ច្បាប់ព្រហ្មទណ្ឌត្រូវយកមកអនុវត្តនៅពេលណា ទីកន្លែង និងបុគ្គលណាខ្លះ។

ជាក់ស្តែងតាមរយៈ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ បានកំណត់ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌជា ២ ផ្នែកគឺ៖

-ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា (ផ្នែកទី១)

-ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ (ផ្នែកទី២)

## ផ្នែកទី១៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា សំដៅដល់ការកំណត់អំពីពេលវេលាដែលត្រូវយកច្បាប់ព្រហ្មទណ្ឌមកអនុវត្ត។

តាមគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌត្រូវយកមកអនុវត្តចំពោះបទល្មើសដែលកើតក្រោយការចូលជាធរមាន នៃច្បាប់ព្រហ្មទណ្ឌប៉ុណ្ណោះ។

ដោយឡែកតាមរយៈ ជំពូកទី២ មាតិកាទី១ គន្ថីទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងអំពីបញ្ញត្តិពិសេសទាក់ទងនឹងពេលនៃការយកច្បាប់ព្រហ្មទណ្ឌមកអនុវត្តជា ៣ ករណីគឺ៖

-ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស (ក)

-ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង (ខ)

-ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង (គ)

## ផ្នែកទី១៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

### ក. ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

តាមរយៈមាត្រា៩ គឺបានបញ្ញត្តិឲ្យយកមកអនុវត្តភ្លាមនូវបទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយ។ មានន័យថា យកបទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសនោះ មកអនុវត្តទាំងចំពោះបទល្មើសដែលបានកើតឡើងក្រោយការចូលជាធរមាន និងមុនការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ដែលយើងហៅថា "គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌថ្មីដែលលុបចោលបទល្មើស"។

## ផ្នែកទី១៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

### ក. ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស ( ត )

តាមរយៈគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌថ្មីដែលលុបចោលបទល្មើសនេះ នាំឲ្យ អំពើ (បទល្មើស) ដែលប្រព្រឹត្តមុនពេលបទប្បញ្ញត្តិថ្មីនោះ ចូលជាធរមាន៖

-មិនអាចធ្វើការចោទប្រកាន់ចំពោះអំពើនោះបាន (ករណីមិនទាន់ចោទប្រកាន់)

-ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅ (ករណីចោទប្រកាន់រួច) គឺត្រូវបញ្ចប់

-ប្រសិនបើមានការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួច ទោសដែលប្រកាសនោះមិនត្រូវអនុវត្ត (ករណីទោសមិនទាន់បានអនុវត្ត) ហើយទោសដែលកំពុងអនុវត្ត គឺត្រូវតែបញ្ចប់ (ករណីទោសកំពុងអនុវត្ត)។

## ផ្នែកទី១៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

### ខ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង

តាម មាត្រា១០ កថាខណ្ឌទី១ បានបញ្ញត្តិអំពី ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង។ ច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ត្រង់ចំណុចនេះ សំដៅដល់ ច្បាប់ព្រហ្មទណ្ឌថ្មី ដែលចែងអំពីទោសមានលក្ខណៈស្រាលជាងច្បាប់ចាស់ (ឧ. ករណីច្បាប់ចាស់បញ្ញត្តិឲ្យផ្តន្ទាទោសពី ២ឆ្នាំ ទៅ ៥ឆ្នាំ រីឯច្បាប់ថ្មីបញ្ញត្តិត្រឹម ១ឆ្នាំ ទៅ ៣ឆ្នាំ)។

# ផ្នែកទី១៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

## ខ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ( ត )

តាមខ្លឹមសារនៃមាត្រានេះ គឺត្រូវយកច្បាប់ព្រហ្មទណ្ឌថ្មីដែលស្រាលជាងយកមកអនុវត្តភ្លាម។ មានន័យថា យកច្បាប់ថ្មីដែលស្រាលជាងនោះមកអនុវត្តទាំងចំពោះបទល្មើសដែលបានកើតឡើងក្រោយការចូលជាធរមាន និងមុនការចូលជាធរមាននៃច្បាប់ថ្មីនោះ ដែលយើងហៅថា "គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌថ្មីដែលស្រាលជាង"។

## ផ្នែកទី១៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

### ខ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង (ត)

តាមរយៈគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌថ្មីដែលស្រាលជាង នាំឲ្យបទល្មើសដែលប្រព្រឹត្តមុនពេលបទប្បញ្ញត្តិថ្មីនោះចូលជាធរមាន ត្រូវអនុវត្តដោយ៖

-យក ទោស របស់ច្បាប់ថ្មីនោះមកអនុវត្ត (ករណីមិនទាន់ចោទប្រកាន់, ចោទប្រកាន់រួច និងករណីមិនទាន់មានការផ្តន្ទាទោសជាស្ថាពរ)។

-ប៉ុន្តែករណីដែលមានការផ្តន្ទាទោសជាស្ថាពររួចហើយ នោះទោសរបស់ច្បាប់ចាស់ត្រូវតែយកមកអនុវត្ត ទោះទោសធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។

## ផ្នែកទី១៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

### គ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង

តាម មាត្រា១០ កថាខណ្ឌទី២ បានបញ្ញត្តិអំពី ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង។ ច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង ត្រង់ចំណុចនេះ សំដៅដល់ ច្បាប់ព្រហ្មទណ្ឌថ្មី ដែលចែងអំពីទោសមានលក្ខណៈធ្ងន់ជាងច្បាប់ចាស់ (ឧ. ករណីច្បាប់ចាស់បញ្ញត្តិឲ្យផ្តន្ទាទោសពី ១ឆ្នាំ ទៅ ៣ឆ្នាំ រីឯច្បាប់ថ្មីបញ្ញត្តិ ២ឆ្នាំ ទៅ ៥ឆ្នាំ)។

តាមខ្លឹមសារនៃមាត្រានេះ បានបញ្ញត្តិឲ្យយកច្បាប់ព្រហ្មទណ្ឌថ្មីដែលធ្ងន់ជាងទៅមកអនុវត្តចំពោះតែបទល្មើសដែលបានកើតឡើងក្រោយការចូលជាធរមាននៃច្បាប់ថ្មីនោះប៉ុណ្ណោះ ដែលហៅថា "គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌថ្មីដែលធ្ងន់ជាង"។

# សន្និដ្ឋាន (ផ្នែកទី១)

ឆ្លងតាមការបកស្រាយខាងលើ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា ចាប់យកគោលការណ៍ធំៗ ២ មកអនុវត្តគឺ៖

-គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ៖ គោលការណ៍នេះត្រូវបានអនុវត្តចំពោះ ១.បទល្មើសដែលកើតក្រោយការចូលជាធរមាននៃច្បាប់ព្រហ្មទណ្ឌ និង ២.ករណីច្បាប់ព្រហ្មទណ្ឌថ្មីធ្ងន់ជាងច្បាប់ចាស់ (ជាហេតុនាំឲ្យមិនមានអានុភាពប្រតិសកម្ម)។

-គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ៖ គោលការណ៍នេះត្រូវយកមកអនុវត្តចំពោះករណីដែល ១.ច្បាប់ថ្មីលុបចោលបទល្មើស និង ២.ច្បាប់ថ្មីស្រាលជាងច្បាប់ចាស់។

## ផ្នែកទី២៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ

ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ សំដៅដល់ការកំណត់អំពីទីកន្លែងដែលត្រូវយកច្បាប់ព្រហ្មទណ្ឌមកអនុវត្ត។

តាមរយៈបញ្ញត្តិដែលមានក្នុង ជំពូកទី៣ មាតិកាទី១ គន្ថីទី១ នៃក្រមព្រហ្មទណ្ឌ បានបែងចែកដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហជា ២ គឺ៖

-ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា (ក)

-ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា (ខ)

## ផ្នែកទី២៖ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ

### ក. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីឲ្យដឹងថា ទីកន្លែងណាខ្លះ គឺជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលច្បាប់កម្ពុជាត្រូវបានយកមកអនុវត្តនៅពេលមានបទល្មើសកើតឡើង យើងអាចធ្វើការសិក្សាទៅលើករណី ២ គឺ៖

-សញ្ញាណទូទៅនៃដែនដីនៃព្រះរាជាណាចក្រកម្ពុជា (ក.១)

-ការចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា (ក.២)

## ក. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

### ក.១. សញ្ញាណទូទៅនៃដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគិតរួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ (មាត្រា១២)។

តាមរយៈ មាត្រា២ នៃរដ្ឋធម្មនុញ្ញ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់នៅក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩។

## ក. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

### ក.២. ការចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ក្រៅពីដែនដីដែលបានបកស្រាយក្នុង (ក.១) ច្បាប់ព្រហ្មទណ្ឌត្រូវយកមកអនុវត្តផងដែរចំពោះទីកន្លែងមួយចំនួន ដែលត្រូវបានចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលមានបទល្មើសបានកើតឡើង។

ដោយទីកន្លែងទាំងនោះមានដូចជា៖

-ក្នុងនាវាកម្ពុជា (មាត្រា១៤)៖ បទល្មើសដែលបានកើតឡើងនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីនាវានោះនៅទីណាក៏ដោយ។

## ក. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

### ក.២. ការចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា (ត)

-ក្នុងនាវាបរទេស (មាត្រា១៥)៖ បទល្មើសដែលបានកើតឡើងនៅក្នុងនាវាបរទេស ដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឲ្យពិនិត្យមើល ឬឲ្យចាប់នាវានោះតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។

-ក្នុងអាកាសយានកម្ពុជា (មាត្រា១៦)៖ បទល្មើសដែលបានកើតឡើងនៅក្នុងអាកាសយានដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ។

## ក. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

### ក.២. ការចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា (ត)

-លើបុគ្គលជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា១៧)៖ ច្បាប់កម្ពុជាត្រូវយកមកអនុវត្តលើបុគ្គលនេះក្នុងករណីដែលបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបានប្រព្រឹត្តនៅឯបរទេស ប៉ុន្តែលុះត្រាតែបំពេញលក្ខខណ្ឌ ២ គឺ៖ ១.បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជាផង និងច្បាប់បរទេសផង ២.អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស។

## ខ.ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់កម្ពុជាត្រូវបានយកមកអនុវត្តចំពោះបទល្មើសដែលកើតឡើងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងករណីដូចជា៖

-ការអនុវត្តច្បាប់ព្រហ្មទណ្ឌដោយឈរលើគោលការណ៍សញ្ជាតិ (ខ.១)

-ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះបទល្មើសប្រឆាំងនឹងកម្ពុជា (ខ.២)

## ខ.ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

### ខ.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដោយឈរលើគោលការណ៍សញ្ជាតិ

ច្បាប់កម្ពុជាត្រូវបានយកមកអនុវត្តចំពោះបទល្មើសដែលកើតឡើងនៅក្រៅដែនដែននៃព្រះរាជាណាចក្រកម្ពុជាក្នុងករណី៖

-បទឧក្រិដ្ឋ ប្រព្រឹត្តដោយពលរដ្ឋខ្មែរ (មាត្រា១៩-១)៖ ច្បាប់កម្ពុជាត្រូវយកមកអនុវត្តនៅគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដី។

-បទមជ្ឈិម ប្រព្រឹត្តដោយពលរដ្ឋខ្មែរ (មាត្រា១៩-២)៖ ច្បាប់កម្ពុជាត្រូវយកមកអនុវត្តបាន លុះត្រាតែអំពើ (បទមជ្ឈិម) នោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។

## ខ.ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

### ខ.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដោយឈរលើគោលការណ៍សញ្ជាតិ (ត)

-ជនរងគ្រោះជាជនជាតិខ្មែរ (មាត្រា២០)៖ ច្បាប់កម្ពុជាត្រូវយកមកអនុវត្តនៅគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាទៅលើពលរដ្ឋខ្មែរ។

* នៅក្នុងករណីដែលមានចែងក្នុង មាត្រា១៩ និង ២០ ខាងលើ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ ហើយត្រូវតែមានបណ្តឹងពីរងគ្រោះ ឬសិទ្ធិវន្ត ឬបណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរ នៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត។

## ខ.ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

## ខ.២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះបទល្មើសប្រឆាំងនឹងកម្ពុជា

តាមរយៈមាត្រា២២ ច្បាប់កម្ពុជាត្រូវបានយកមកអនុវត្តចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដែននៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីបទល្មើសនោះជា៖

១-បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា

២-បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា

៣-បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅកម្ពុជា

៤-បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃកម្ពុជា

៥-បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។

## សន្និដ្ឋាន (ផ្នែកទី២)

ឆ្លងតាមការបកស្រាយក្នុងផ្នែកទី២ ខាងលើ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ គឺត្រូវបានអនុវត្តជា ២ករណី គឺ៖

-ក្នុងដែនដី

-ក្រៅដែនដី (១.គោលការណ៍សញ្ជាតិ និង ២.បទល្មើសប្រឆាំងនឹងកម្ពុជា)។

# គំនូសបំព្រួញខ្លឹមសារសង្ខេប

- ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ
  - ការអនុវត្តក្នុងពេលវេលា
    - ច្បាប់ថ្មីដែលលុបចោលបទល្មើស មាត្រា៩ → គោលការណ៍ប្រតិសកម្ម
    - ច្បាប់ថ្មីដែលស្រាលជាង មាត្រា១០-១ → គោលការណ៍ប្រតិសកម្ម
    - ច្បាប់ថ្មីដែលធ្ងន់ជាង មាត្រា១០-២ → គោលការណ៍មិនប្រតិសកម្ម
  - ការអនុវត្តនៅក្នុងលំហ
    - ក្នុងដែនដី
      - ដែនអធិបតេយ្យ
      - ចាត់ទុកថាក្នុងដែនដី
        - ក្នុងនាវាកម្ពុជា មាត្រា១៤
        - ក្នុងនាវាបរទេស មាត្រា១៥
        - ក្នុងអាកាសយានកម្ពុជា មាត្រា១៦
        - អ្នកផ្ដើមគំនិត ឬសមគំនិតនៅកម្ពុជា មាត្រា១៧
    - ក្រៅដែនដី
      - គោលការណ៍សញ្ជាតិ
        - ជនល្មើសជាជនជាតិខ្មែរ (បទឧក្រិដ្ឋ ឬមជ្ឈិម) មាត្រា១៩
        - ជនរងគ្រោះជាជនជាតិខ្មែរ (បទឧក្រិដ្ឋ) មាត្រា២០
      - បទល្មើសប្រឆាំងកម្ពុជា មាត្រា២២

## ឯកសារយោង

-រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

-សេចក្ដីព្រាងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៥

-បាឋកថា ស្ដីពី គោលការណ៍គ្រឹះធំៗនៃក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ (ឯកឧត្ដម កើត រិទ្ធ)

# សូមអរគុណ !

លោកអ្នកអាចធ្វើការទាញយកនូវឯកសារនានាបន្ថែមទៀតតាមរយៈគេហទំព័រខាងក្រោម

https://www.facebook.com/kh.lawpage

https://www.laws-page.blogspot.com